**សកម្មភាព** ៖ **ល្បែងលេងឧបករណ៍តន្ត្រី** (ល្បែងលេងឧបករណ៍តន្ត្រីនេះត្រូវបានយកឧបករណ៍តន្ត្រីពី "ល្បែងបង្កើតឧបករណ៍តន្ត្រី" មកឱ្យក្មេងៗប្រគុំលេង)

**សិក្សាសង្គម**

ចម្រៀង និងតន្ត្រី (ចំណេះដឹងបច្ចេកទេស ការថ្លៃប្រឌិត) (បទពិសោធផ្នែកតន្ត្រី)

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់ពីចំណាងជើងបទចម្រៀងមួយចំនួន និងរបៀបធ្វើកាយវិការ។

ប្រាប់ពីរបៀបទះដៃបន្ទរ ឬ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប្រមូលឧបករណ៍តន្ត្រីដែលក្មេងបានធ្វើវា និងដាក់វានៅលើតុរបស់ក្មេងៗ

**ការរៀបចំ** ៖

- ជ្រើសរើសបទចម្រៀងដែលអ្នកត្រូវការប្រើនៅក្នុងការលេងល្បែងមួយនេះ
- រៀនពាក្យ៖ ពីឈ្មោះឧបករណ៍តន្ត្រី មួយចំនួន ។

**សេក្តីណែនាំ៖**

1. សួរក្មេងៗថា៖ តើដូរ្យតន្ត្រីគឺជាអ្វី?
2. សរសេរវានៅលើក្តារខៀន «ដូរ្យតន្ត្រី»ហើយឱ្យក្មេងៗថាតាមពាក្យ«ដូរ្យតន្ត្រី» ។
3. ពិភាក្សាពីការងារជាអ្នកលេងដូរ្យតន្ត្រី៖តើកូនៗធ្លាប់បានលឺការប្រគុំតន្ត្រីនៅកន្លែងណាខ្លះ?
4. ប្រាប់ក្មេងៗថា៖ កូនៗនឹងរៀនធ្វើជា «អ្នកលេងដូរ្យតន្ត្រីតន្ត្រី» នៅក្នុងមេរៀននេះ។
5. កូនៗត្រូវលេងឧបករណ៍តន្ត្រីដែលកូនធ្លាប់បានធ្វើពីមុនមក (ដើម្បីឱ្យក្មេងៗដទៃទៀតបានលឺ)។
6. ប្រាប់ក្មេងៗថា៖កូនៗត្រូវប្រើឧបករណ៍តន្ត្រីនេះបង្កើតជា "ចង្វាក់ភ្លេង" តាមបទចម្រៀង។
7. ត្រូវមានបទចម្រៀង ២ ៣ បទសម្រាប់ក្មេងៗជ្រើស ៖ តើបទមួយណាដែលកូនៗចូលចិត្ត?
8. សរសេរពាក្យ "ចង្វាក់ភ្លេង" នៅលើក្តារខៀន។
   សួរក្មេងៗថា៖តើកូនៗយល់អត្ថន័យរបស់ពាក្យ "ចង្វាក់ភ្លេង" ដែរឬទេ?
9. បង្ហាញក្មេងៗពីការទះដៃធ្វើជា "ចង្វាក់ភ្លេង" តាមបទចម្រៀងទាំងអស់គ្នាជាមួយអ្នកគ្រូ។

10. បន្ទាប់មកឱ្យក្មេងៗជ្រើសយកឧបករណ៍តន្ត្រីលេងជា "ចង្វាក់ភ្លេង" តាមបទចម្រៀង ចំណែកឯអ្នកគ្រូទះដៃ។
11. បន្ទាប់ពីលេងរួចត្រូវត្រូវឱ្យកូនៗត្រូវតែទុកដាក់ឧបករណ៍តន្ត្រី នៅកន្លែងដើមវិញ ដើម្បីកុំឱ្យបាក់បែក។